# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២៨៩ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២១/៥៦៤ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថល
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៦៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ ស្តីពីការផ្លាស់ប្តូរទិន្នន័យតាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា
- បានឃើញអនុក្រឹត្យលេខ២២០ អនក្រ.បក ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល
- បានឃើញអនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់បែបបទនិងនីតិវិធីនៃការចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដើម្បីកំណត់អត្តសញ្ញាណ ប្រភេទការងារ មុខរបរ អាជីវកម្ម និងព័ត៌មានរបស់អ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ សំដៅចូលរួមអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឱ្យរីកធំធាត់ និងអាចចូលរួមបានពេញលេញប្រកបដោយចីរភាព បរិយាបន្ន និងភាពធន់។

**មាត្រា២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះការចុះឈ្មោះសហគ្រាសធុនមីក្រូ កម្មករ និយោជិតនៃសហគ្រាសធុនមីក្រូ កម្មករនិយោជិតម្តងម្កាល និងបុគ្គលស្វ័យនិយោជន៍ដែលប្រកបអាជីវកម្ម មុខរបរ និង/ឬការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

**មាត្រា៣.-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

**កម្មករនិយោជិត** សំដៅដល់ជនគ្រប់ភេទដែលបានចុះកិច្ចសន្យាធ្វើការយកកម្រៃក្រោមការដឹកនាំនិងគ្រប់គ្រងរបស់បុគ្គលម្នាក់ទៀតជារូបវន្តបុគ្គលឬនីតិបុគ្គលសាធារណៈឬឯកជន។

**កម្មករនិយោជិតម្តងម្កាល** សំដៅដល់ជនដែលចុះកិច្ចសន្យាធ្វើការមួយជាប្រាកដ តាមធម្មតាត្រូវតែឱ្យហើយក្នុងរយៈពេលយ៉ាងខ្លី និងធ្វើការមួយពេលៗ ធ្វើឈប់ៗ និងធ្វើមួយរដូវៗ។

**តំបន់នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ** សំដៅដល់គ្រប់សកម្មភាពអាជីវកម្ម មុខរបរ និងការងារដែល (១) មិនមែនជាសកម្មភាពខុសច្បាប់ និង (២) មិនមានការបំពេញបែបបទរដ្ឋបាលដែលនាំឱ្យមានការលំបាកក្នុងការកំណត់អត្តសញ្ញាណ។

**តំបន់នៃការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ** សំដៅដល់លទ្ធភាពរបស់អ្នកប្រកបមុខរបរនិងធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធមានកម្រិតនិងមិនអាចបំពេញបែបបទពេញលេញដើម្បីចូលទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធបាន ដូច្នេះត្រូវមានការបង្កើតតំបន់នេះឡើងដោយមានការតម្រូវឱ្យមានការបំពេញបែបបទរដ្ឋបាលគោលខ្លះ តែមិនមានការបង់កម្រៃសេវាដើម្បីងាយស្រួលក្នុងការកំណត់អត្តសញ្ញាណហើយទទួលបាននូវការថែបំប៉ន និងអត្ថប្រយោជន៍ផ្សេងៗ ដើម្បីឈានចូលទៅក្នុងតំបន់នៃសេដ្ឋកិច្ចក្នុងប្រព័ន្ធ។

**ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (Cambodia Data Exchange–CamDX)** សំដៅដល់ថ្នាលបច្ចេកវិទ្យាព័ត៌មានរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវបានបង្កើតឡើងសម្រាប់ផ្លាស់ប្តូរទិន្នន័យ ដោយប្រើប្រាស់សន្ទានកម្មនៃកម្មវិធីកុំព្យូទ័ររវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយនិងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយទៀតក្នុងវិស័យសាធារណៈ និងជាមួយវិស័យឯកជនដែលជាសមាជិករបស់ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា ដោយសុវត្ថិភាពតាមរយៈប្រព័ន្ធអ៊ីនធឺណិតឬបណ្តាញតភ្ជាប់ឌីជីថលផ្សេងៗ។

**បុគ្គលស្នើសុំ** សំដៅដល់រូបវន្តបុគ្គលដែលដាក់ពាក្យស្នើសុំការចុះឈ្មោះជាអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធដោយបំពេញបែបបទនិងលក្ខខណ្ឌតម្រូវដែលមានកំណត់ក្នុងអនុក្រឹត្យនេះ ព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**បុគ្គលស្វ័យនិយោជន៍** សំដៅដល់ជនដែលប្រកបការងារឬមុខរបររកចំណូលផ្ទាល់ខ្លួនដោយមិនពាក់ព័ន្ធនឹងប្រាក់ឈ្នួលឬប្រាក់បៀវត្សដែលផ្តល់ដោយនិយោជកឬរដ្ឋតាមកិច្ចសន្យាការងារ ហើយក៏មិនមានប្រើប្រាស់កម្មករនិយោជិតនៅក្នុងសកម្មភាពការងារឬមុខរបររបស់ខ្លួន។

**ភ្នាក់ងារចុះឈ្មោះ** សំដៅដល់ស្ថាប័នក្នុងវិស័យសាធារណៈ ឬវិស័យឯកជន ឬស្ថាប័នពាក់ព័ន្ធដទៃទៀតដែលអាចផ្តល់សេវាស្នើសុំការចុះឈ្មោះជាអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធតាមរយៈថ្នាលឌីជីថល សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឬប្រព័ន្ធដែលមានស្រាប់របស់ភ្នាក់ងារចុះឈ្មោះ និងដែលបានចុះអនុស្សរណៈនៃការយោគយល់ជាមួយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល។

**សហគ្រាសធុនមីក្រូ** សំដៅដល់សហគ្រាសអាជីវកម្មគ្រប់ប្រភេទ ដែលមានផលរបរប្រចាំឆ្នាំក្រោម ៦២២៥០ដុល្លារអាម៉េរិក ឬមានចំនួនកម្មករ និយោជិតក្រោម៥នាក់។

**ឯកសារទម្រង់ឌីជីថល** សំដៅដល់ឯកសារដែលមានទម្រង់ជាPortable Document Format(PDF) ឬរូបភាពសម្រាប់ប្រើប្រាស់ជាឯកសារយោងឬភ្ជាប់ ដែលបានស្កេនឬថតចេញពីឯកសាររូបីឬឯកសារដែលមានទម្រង់ជាPDFឬរូបភាព ដែលប្រើប្រាស់សម្រាប់បោះពុម្ពប្រើប្រាស់ជាផ្លូវការបាន។

**សន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ(Application Programming Interface ឬហៅកាត់ថា API)** សំដៅដល់ច្រកចេញចូលស្តង់ដាដែលអនុញ្ញាតឱ្យទិន្នន័យអាចផ្លាស់ប្តូរពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយផ្សេងទៀត។ ការផ្លាស់ប្តូរទិន្នន័យ គឺតម្រូវឱ្យស្របតាមលក្ខខណ្ឌដែលបានកំណត់។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៤.-**

គណៈកម្មាធិការសម្របសម្រួលការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ជាស្ថាប័នគោលមានសមត្ថកិច្ចដឹកនាំតម្រង់ទិស និងសម្របសម្រួលការងារចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងមានសិទ្ធិចេញវិញ្ញាបនបត្រចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល ជាប្រតិបត្តិករថ្នាលឌីជីថលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាស្ថាប័នមានសមត្ថកិច្ចក្នុងការទទួលត្រួតពិនិត្យនិងឆ្លើយតបពាក្យស្នើសុំចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

**មាត្រា៥.-**

គណៈកម្មាធិការសម្របសម្រួលការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធមានភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំ តម្រង់ទិស សម្របសម្រួល ផ្សព្វផ្សាយ បញ្ជ្រាបការយល់ដឹង ដើម្បីជំរុញការស្នើសុំការចុះឈ្មោះតាមថ្នាលឌីជីថល សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព
- ពិនិត្យ តាមដាន វាយតម្លៃ និងរកដំណោះស្រាយចំពោះបញ្ហាប្រឈមនៃការចុះឈ្មោះតាមថ្នាលឌីជីថលសម្រាប់ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- ចេញវិញ្ញាបនបត្រចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ

- ធ្វើរបាយការណ៍ប្រចាំឆ្នាំជូនរាជរដ្ឋាភិបាលអំពីវឌ្ឍនភាពនិងលទ្ធផលនៃការងារចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

**មាត្រា៦ .-**

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថលមានភារកិច្ច ដូចខាងក្រោម៖

- អភិវឌ្ឍ ថែទាំ និងធ្វើបច្ចុប្បន្នកម្មតាមការចាំបាច់នូវថ្នាលឌីជីថលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- រៀបចំជួសជុលចំណុចខ្វះខាតរបស់ប្រព័ន្ធនិងដោះស្រាយបញ្ហាបច្ចេកទេស
- រៀបចំយន្តការសុវត្ថិភាពថ្នាលឌីជីថលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឱ្យបានរឹងមាំ ដើម្បីការពារនិងទប់ស្កាត់ការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិតទៅលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- ចូលរួមរៀបចំនិងគ្រប់គ្រងមជ្ឈមណ្ឌលទិន្នន័យ ដោយធានាឱ្យបាននូវប្រតិបត្តិការនិងសុវត្ថិភាពប្រព័ន្ធទាំងមូលជាអតិបរមា
- ផ្តល់ប្រឹក្សាបច្ចេកទេសដល់ក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការចូលរួមការងារចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- រៀបចំវគ្គបណ្តុះបណ្តាលក្នុងការប្រើប្រាស់ថ្នាលដល់ភ្នាក់ងារចុះឈ្មោះនិងស្ថាប័នពាក់ព័ន្ធ
- រៀបចំយុទ្ធនាការផ្សព្វផ្សាយនិងយន្តការគាំទ្រអ្នកប្រើប្រាស់លើការប្រើប្រាស់ប្រព័ន្ធ
- សហការសម្របសម្រួលនិងរៀបចំធ្វើកិច្ចសហប្រតិបត្តិការជាមួយតួអង្គពាក់ព័ន្ធ ដើម្បីជួយស្នើសុំការចុះឈ្មោះជាអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- គ្រប់គ្រងទិន្នន័យអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលត្រូវបានចុះឈ្មោះតាមថ្នាលឌីជីថលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងចែករំលែកទិន្នន័យជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជនតាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា ក្នុងគោលបំណងបម្រើដល់ប្រយោជន៍សាធារណៈ រៀបចំកញ្ចប់អត្ថប្រយោជន៍ និងតាមដានស្ថានភាពសេដ្ឋកិច្ច
- ផ្តល់របាយការណ៍វឌ្ឍនភាពការងារប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនគណៈកម្មាធិការសម្របសម្រួលការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

**មាត្រា៧ .-**

ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌមានភារកិច្ច ដូចខាងក្រោម៖

- ទទួលត្រួតពិនិត្យនិងឆ្លើយតបពាក្យស្នើសុំ ក្នុងរយៈពេលដូចកំណត់ក្នុងជំពូកទី៣នៃអនុក្រឹត្យនេះ
- ជូនដំណឹងដល់បុគ្គលស្នើសុំដើម្បីធ្វើការកែតម្រូវឬបំពេញបន្ថែមពាក្យស្នើសុំ ក្នុងករណីដែលព័ត៌មាននិង/ឬឯកសារតម្រូវមិនត្រឹមត្រូវនិង/ឬមិនគ្រប់គ្រាន់
- ធានាបាននូវតម្លាភាពនិងសុក្រឹតភាពនៃការត្រួតពិនិត្យនិងឆ្លើយតបលើពាក្យស្នើសុំ
- ផ្តល់របាយការណ៍វឌ្ឍនភាពការងារប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនគណៈកម្មាធិការសម្របសម្រួលការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

គណៈកម្មាធិការសម្របសម្រួលការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធមានភារកិច្ចទទួលត្រួតពិនិត្យ និងឆ្លើយតបពាក្យស្នើសុំចុះឈ្មោះ រហូតដល់ពេលដែលការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ បានត្រៀមលក្ខណៈរួចរាល់ក្នុងការបំពេញភារកិច្ចនេះ ឬមានការសម្រេចដោយឡែកផ្សេងទៀតរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## បែបបទនិងនីតិវិធីនៃការចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ
### ផ្នែកទី១
### បែបបទនៃការចុះឈ្មោះ

**មាត្រា៨ ..**

ដើម្បីបំពេញលក្ខខណ្ឌគ្រប់គ្រាន់ក្នុងការស្នើសុំការចុះឈ្មោះ បុគ្គលស្នើសុំត្រូវផ្តល់ព័ត៌មានអំពីអត្តសញ្ញាណ ព័ត៌មានសេដ្ឋកិច្ច ព័ត៌មានអប់រំ រូបថតអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរច្បាប់ដើម រូបថតផ្ទៃមុខ រូបថតផ្ទៃមុខជាមួយទីតាំងអាជីវកម្ម រូបថតសកម្មភាពអាជីវកម្ម និងព័ត៌មានផ្សេងៗ ដែលត្រូវកំណត់លម្អិតក្នុងនីតិវិធីប្រតិបត្តិស្តង់ដារបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល។

ព័ត៌មាននិងឯកសារតម្រូវទាំងអស់ ត្រូវបំពេញឬបញ្ចូលទៅក្នុង**«ថ្នាលឌីជីថលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ»** ក្នុងទម្រង់អេឡិចត្រូនិកដោយបុគ្គលស្នើសុំផ្ទាល់ តាមរយៈកម្មវិធីទូរស័ព្ទដៃCam-IE ដែលអាចទាញយកបានលើApp Store ឬGoogle Play Store ឬគេហទំព័រwww.informal.digitaleconomy.gov.kh ឬដោយភ្នាក់ងារចុះឈ្មោះអាចស្វែងរកបាននៅក្នុងគេហទំព័រwww.informal.digitaleconomy.gov.kh។

**មាត្រា៩ ..**

ព័ត៌មាននិង/ឬឯកសារតម្រូវទាំងអស់សម្រាប់ការស្នើសុំការចុះឈ្មោះ ត្រូវបញ្ជូនដល់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ដូចមានចែងក្នុងជំពូកទី២ នៃអនុក្រឹត្យនេះ តាមថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា(Cambodia Data Exchange-CamDX) សម្រាប់ជាកម្មវត្ថុនៃការពិនិត្យនិងសម្រេចផ្តល់ការចុះឈ្មោះ។

ក្រសួង ស្ថាប័នមានសមត្ថកិច្ចត្រូវពិនិត្យលើភាពត្រឹមត្រូវនៃព័ត៌មាននិងឯកសារតម្រូវ ក្នុងរយៈពេលដូចកំណត់ក្នុងផ្នែកទី២ ជំពូកទី៣ នៃអនុក្រឹត្យនេះ និងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា១០ ..**

ការស្នើសុំការចុះឈ្មោះឬការផ្តល់សេវាស្នើសុំការចុះឈ្មោះដោយភ្នាក់ងារចុះឈ្មោះ មិនមានការយកកម្រៃសេវា។

### ផ្នែកទី២
### នីតិវិធីនៃការចុះឈ្មោះ

**មាត្រា១១ ..**

ក្នុងរយៈពេលយ៉ាងយូរ១(មួយ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានការស្នើសុំ ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យលើភាពត្រឹមត្រូវនៃព័ត៌មាននិងឯកសារតម្រូវដែលត្រូវបានបំពេញ ក្នុងករណី៖

- ពិនិត្យឃើញថា ព័ត៌មាននិង/ឬឯកសារតម្រូវគ្រប់គ្រាន់និងត្រឹមត្រូវ ត្រូវផ្តល់ការចុះឈ្មោះ។ ក្នុងករណីនេះ បុគ្គលស្នើសុំនឹងទទួលបាន**«វិញ្ញាបនបត្រចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ»** ក្នុងទម្រង់ឌីជីថល ដែលអាចបោះពុម្ពបានតាមថ្នាលឌីជីថលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធសម្រាប់ប្រើប្រាស់ជាផ្លូវការ ដូចមានចែងក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ
- ពិនិត្យឃើញថា ព័ត៌មាននិង/ឬឯកសារតម្រូវមិនគ្រប់គ្រាន់និងមិនត្រឹមត្រូវ ត្រូវបញ្ជូនពាក្យស្នើសុំជូនអ្នកដាក់ពាក្យស្នើសុំវិញ ដោយបញ្ជាក់ពីមូលហេតុច្បាស់លាស់ដើម្បីជាមូលដ្ឋានក្នុងការកែតម្រូវ

- ពិនិត្យឃើញថា ព័ត៌មាននិង/ឬឯកសារតម្រូវមានការក្លែងបន្លំឬមិនស្ថិតក្នុងវិសាលភាពអនុវត្តនៃអនុក្រឹត្យនេះ ឬក្រោមហេតុផលសមរម្យផ្សេងទៀត ដូចមានចែងលម្អិតក្នុងនីតិវិធីប្រតិបត្តិស្តង់ដារបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល ត្រូវបដិសេធដោយបញ្ជាក់ពីមូលហេតុច្បាស់លាស់។

**មាត្រា១២ .-**

វិញ្ញាបនបត្រចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធបញ្ជាក់អំពីអត្តសញ្ញាណនិងប្រភេទអាជីវកម្ម មុខរបរ និង/ឬការងាររបស់បុគ្គលស្នើសុំ ព្រមទាំងបញ្ជាក់ស្ថានភាពថា បុគ្គលស្នើសុំត្រូវបានចុះឈ្មោះជាអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

វិញ្ញាបនបត្រចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធមានការទទួលស្គាល់ពីរាជរដ្ឋាភិបាល ហើយគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវធ្វើការផ្សព្វផ្សាយ ព្រមទាំងជំរុញនិងលើកទឹកចិត្តដើម្បីឱ្យឯកសារនេះមានការទទួលស្គាល់និងការប្រើប្រាស់បានទូលំទូលាយទាំងក្នុងវិស័យសាធារណៈនិងឯកជន។

**មាត្រា១៣ .-**

នីតិវិធីនៃការអនុវត្តការចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ នឹងមានចែងលម្អិតនៅក្នុងនីតិវិធីប្រតិបត្តិស្តង់ដាដែលរៀបចំដោយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល។

## ផ្នែកទី៣
## ក្រមសីលធម៌និងការសម្ងាត់វិជ្ជាជីវៈ

**មាត្រា១៤ .-**

បុគ្គលស្នើសុំត្រូវធានាអះអាងតាមទម្រង់អេឡិចត្រូនិកថា ព័ត៌មាននិងឯកសារតម្រូវដែលខ្លួនបានផ្តល់សម្រាប់ស្នើសុំការចុះឈ្មោះ ពិតជាព័ត៌មាននិងឯកសារត្រឹមត្រូវ និងមិនក្លែងបន្លំ។ ក្នុងករណីដែលព័ត៌មាននិងឯកសារទាំងនោះមិនត្រឹមត្រូវឬមានការក្លែងបន្លំ ក្រសួង ស្ថាប័នមានសមត្ថកិច្ចត្រូវចាត់វិធានការតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា១៥ .-**

មន្ត្រីអនុវត្តការងារពាក់ព័ន្ធនឹងការចុះឈ្មោះ និងភ្នាក់ងារចុះឈ្មោះ ត្រូវគោរពឱ្យបានខ្ជាប់ខ្ជួននូវក្រមសីលធម៌វិជ្ជាជីវៈ ដែលកំណត់ដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច និងស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលព្រមទាំងលិខិតបទដ្ឋានគតិយុត្តជាធរមានដទៃទៀត។

មន្ត្រីអនុវត្តការងារពាក់ព័ន្ធនឹងការចុះឈ្មោះ និងភ្នាក់ងារចុះឈ្មោះទាំងអស់ ត្រូវរក្សាការសម្ងាត់ លើកលែងតែមានការតម្រូវដោយច្បាប់ ឬស្ថាប័នមានសមត្ថកិច្ច ឬសេចក្តីសម្រេចរបស់តុលាការ។

## ជំពូកទី៤
## សិទ្ធិនិងករណីយកិច្ចរបស់អ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ
## ផ្នែកទី១
## សិទ្ធិរបស់អ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ

**មាត្រា១៦ .-**

គ្រប់រូបវន្តបុគ្គលដែលត្រូវបានចុះឈ្មោះជាអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ មានលទ្ធភាពទទួលបានការលើកទឹកចិត្តនិងការថែបំប៉នផ្សេងៗពីក្រសួង ស្ថាប័នពាក់ព័ន្ធ ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ផ្នែកទី២
## ករណីយកិច្ចរបស់អ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ

**មាត្រា១៧.-**

គ្រប់រូបវន្តបុគ្គលដែលត្រូវបានចុះឈ្មោះជាអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ មានករណីយកិច្ច ដូចខាងក្រោមៈ

- បំពេញបែបបទនិងលក្ខខណ្ឌតម្រូវដែលមានកំណត់ក្នុងអនុក្រឹត្យនេះ ដើម្បីស្នើសុំការចុះឈ្មោះ
- ផ្តល់ព័ត៌មាននិងឯកសារតម្រូវឱ្យបានគ្រប់គ្រាន់ ត្រឹមត្រូវ និងមិនមានការក្លែងបន្លំ
- ធ្វើបច្ចុប្បន្នកម្មព័ត៌មាននិងឯកសារតម្រូវក្នុងករណីចាំបាច់។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សៅរ៍ ១៤កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួលៈ**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ